សេចក្តីព្រាងចុងក្រោយ

# ផែនការសកម្មភាពរបស់បណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ តំបន់អាស៊ីអាគ្នេយ៍

រៀបរៀងដោយ

វេជ្ជបណ្ឌិត រ៉ូមី គីយ៉ាណូ PAN-Philippines និង
លោក ម៉ាននី កាឡូនហ្សូ GAIA

## មាតិការ


១. សេចក្តីផ្តើម

១.១ ប្រវត្តិ

១.២ អង្គការ GAIA និង PAN-Philippines

១.៣ IPEP សេចក្តីព្យាយាមថ្នាក់សាកល ជាតិ និង តំបន់

១.៤ បណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ IPEN

១.៥ ការស្ទាបស្ទង់ថ្នាក់តំបន់

២. លទ្ធផលស្ទាបស្ទង់

២.១ សុខភាព និងឥទ្ធិពលសារធាតុគីមី

២.១.១ ថ្នាំពុលកសិកម្ម

២.១.២ សំរាម

២.១.៣ ការសាយភាយ POPs: ឌីអុកស៊ីន និង POPsកើតដោយអចេតនា

២.១.៤ សម័យការរីកចំរើនសេដ្ឋកិច្ច និងសារធាតុគីមីប្រកបដោយសុវត្ថិភាព

២.២ គោលការណ៍ ឧបករណ៍ និងយុទ្ធសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាល

២.២.១ ការបង្កើនការយល់ដឹង

២.២.២ បណ្តាញការងាររបស់អង្គការមិនមែនរដ្ឋាភិភាល

២.២.៣ ការចូលរួមនយោបាយ: ការចូលរួមពីអន្តរជាតិ និង ជាតិ

២.២.៤ ការតាមដាន

២.២.៥ ការជំរុញ និងវិស្សកម្មសុវត្ថិភាព - ជំរើសផ្សេងៗដែលមិនពុល

២.២.៦ ការអភិវឌ្ឍស្ថាប័ន

៣. ផែនការសកម្មភាពក្នុងតំបន់ : ឱកាស និង តំរូវការ

៣.១ គ្រោងការណ៍យុទ្ធសាស្ត្ររបស់ NGO តំបន់

៣.១.១ ការពង្រឹង ការទំនាក់ទំនង ការសហការ និងការចែកចាយពតិមានរបស់អន្តរអង្គការមិនមែនរដ្ឋាភិបាល

*ប្រភេទការងារ*

៣.១.២ ការពិភាក្សារកិច្ចព្រមព្រៀង និងនយោបាយអន្តរជាតិ សំរាប់ការងារជាតិ

*ប្រភេទកាងារ*

៣.២ តំរូវការរបស់ NGO នៅថ្នាក់មូលដ្ឋាន

៣.២.១ កសាងសមត្ថភាព និងបណ្តុះបណ្តាល

*ប្រភេទកាងារ*

៣.២.២ ការបណ្តុះបណ្តាលអភិវឌ្ឍស្ថាប័ន

*ប្រភេទកាងារ*

៣.២.៤ ការតាមដាន: បរិស្ថាន និងមនុស្ស : បង្កើតទិន្នន័យ

*ប្រភេទកាងារ*

៤. សេចក្តីបញ្ចប់

## ១. សេចក្ដីផ្ដើម

ការផលិតកន្លងមកនិងបច្ចុប្បន្ន ការប្រើប្រាស់ និងការបោះចោល នូវសារធាតុគីមីពុល និងសារធាតុគ្រោះថ្នាក់ កំពុងតែកើនឡើងនូវឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ដ៏ធំធេងដល់មនុស្ស និងបរិស្ថានធម្មជាតិ ។ ម្យ៉ាងទៀត អ្នកក្រីក្រ ស្ត្រី កុមារ កម្មករ និងជនជាតិភាគតិច គឺតែងតែងាយរងគ្រោះដោយសារធាតុគីមីពុល ហើយក្លាយជាជនរងគ្រោះផ្នែកសុខភាពគួរឱ្យកាត់សំគាល់ដូចជា ការបន្តពូជ និងការលូតលាស់មិនប្រក្រតី (រួមមាន បញ្ហាកំណើត និងការធំធាត់ប្រពន្ធ័ប្រសាទ) ជំងឺមហារីក ការប្រែប្រួលសែន និងការចុះខ្សោយមុខងារភាពស៊ាំ និងក្រពេញ ។ អង្គការមិនមែនរដ្ឋាភិបាល(NGO)លើពិភពលោកបានឆ្លើយតបទៅនឹងការគំរាមកំហែង និងផលគ្រោះថ្នាក់បង្កឡើងដោយសារធាតុគីមីពុលតាមរយៈសកម្មភាព និងគោលការណ៍ផ្សេងៗ ។ ផែនការសកម្មភាពតំបន់នេះបង្កើតឡើងនូវសកម្មភាពរួមគ្នាជាង ១០ ឆ្នាំមកហើយ ទាក់ទងនឹងអនុសញ្ញាស្តុកខូមស្តីពី សារធាតុសរីរាង្គពុលមិនងាយបំបែកធាតុ (POPs) ដូចជា បណ្តាញការងារ NGO ជាមួយបណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ (IPEN) និងបណ្តាញការងារ NGOដទៃទៀត ដែលរួមចំណែកក្នុងគោលដៅ *អនាគតគ្មានជាតិពុល* ។ បណ្តាញការងារនឹងផ្តល់រូបភាពការងារ និង អាទិភាពការងារដូចជា ការចាប់ផ្តើមផែនការសហការដើម្បីអនាគតមួយដែលការផលិត ការប្រើប្រាស់ និងការបោះចោលសារធាតុគីមីមិនមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស បរិស្ថានធម្មជាតិ សេដ្ឋកិច្ចសហគម និង ប្រពៃណីវប្បធម៌របស់យើង។

### ១.១ ប្រវត្តិ

អនុសញ្ញាស្តុកខូមស្តីពី សារធាតុសរីរាង្គពុលមិនងាយបំបែកធាតុ បានចូលរួមពីសហគមអន្តរជាតិ ដើម្បីដោះស្រាយបញ្ហា POPs និង បង្កើនការយល់ដឹងយ៉ាងទូលំទូលាយ អំពីបញ្ហាសុវត្ថិភាពសារធាតុគីមីដែលកំពុងជួបប្រទះសព្វថ្ងៃក្នុងតំបន់អាស៊ី និងតំបន់ផ្សេងៗទៀត ។ អនុសញ្ញាត្រូវបានអនុមតិនៅឆ្នាំ ២០០៣ ពេលនោះ IPEN បានអនុវត្តគម្រោងជាង ២៥០ យ៉ាងជោគជ័យនៅក្នុងប្រទេសចំនួន ៦៥ គាំទ្រដល់ការចូលរួមរបស់សង្គមស៊ីវិល ក្នុងដំណើរការរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា តាមរយៈគម្រោងលុបបំបាត់ POPs អន្តរជាតិ (IPEP) ។ គម្រោងនេះបានជួយ NGOsនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាស្នូលតំបន់ដើម្បីសម្របសម្រួលការចូលរួម និង ការអនុវត្តគម្រោងរបស់ NGO ក្នុងគម្រោង។ នៅតំបន់អាស៊ីអាគ្នេយ៍មានអង្គការសម្ពន្ធ័ភាពរួមសំរាប់ជម្រើសឡដុតរំលាយ (GAIA) និងបណ្តាញសកម្មភាពថ្នាំពុលកសិកម្ម-ហ្វីលីពីន (PAN-Philippines) ជាតំណាងបណ្តាញការងារលុបបំបាត់ POPs តំបន់ អាស៊ីអាគ្នេយ៍ (SEAPEN) ។

គម្រោង IPEP បានបញ្ចប់នៅ ឆ្នាំ ២០០៦ ហើយ អង្គការ PAN-Philippines និង GAIA សហការជាមួយលេខាធិការដ្ឋាន IPENបានធ្វើការស្ទាបស្ទង់ NGOs និងសង្គមស៊ីវិល ក្នុងទូទាំងតំបន់អាស៊ីអាគ្នេយ៍ក្នុងគោលបំណង :

- ជំរុញឱ្យអន្តរៈ NGOs និងសង្គមស៊ីវិល ក្នុងតំបន់ សន្ទនា និងទំនាក់ទំនងគ្នា
- សង្ខេបពីស្ថានភាពបច្ចុប្បន្ននៃសុវត្ថិភាពសារធាតុគីមីក្នុងតំបន់

- កំណត់អាទិភាពបញ្ហាសារធាតុគីមីសំខាន់ៗ ដែលអាចដោះស្រាយដោយ **NGOs** និងសង្គមស៊ីវិល និង
- បង្កើតផែនការសកម្មភាពសំរាប់តំបន់អាស៊ីអាគ្នេយ៍

## ១.២ អង្គការ GAIA និង PAN-Philippines

បណ្តាញការងារលុបបំបាត់ POPs តំបន់អាស៊ីអាគ្នេយ៍(SEAPEN) ជួយសម្រួលដំណើរការភ្ជាប់គ្នារវាងNGOs ក្នុងតំបន់ ។ អង្គការ PAN-Philippines និង GAIA រួមកម្លាំងឋាមពល និងជំនាញការរបស់ខ្លួនធ្វើស្នូលនៃ IPEP តំបន់អាស៊ីអាគ្នេយ៍ ។

PAN-Philippines ជាអង្គការមិនមែនរដ្ឋាភិបាលធ្វើការជាមួយសាធារណជនលើបញ្ហាថ្នាំពុលកសិកម្ម សុខភាពសាធារណៈ និងបរិស្ថាន ច្រើនជាងមួយទសវត្សរ៍មកហើយ ។ អង្គការនេះជាចំណែកមួយរបស់បណ្តាញការងារសកម្មភាពថ្នាំពុលកសិកម្មអន្តរជាតិ បានរួមចំណែកក្នុងយុទ្ធនាការប្រឆាំងនឹងថ្នាំពុលកសិកម្មដែលពុលខ្លាំង ដូចជា អង់ដូស៊ុលហ្វាន មេទីលប៉ារ៉ាស្យុង ទ្រីផេនីលទីន ម៉ូណូក្រូតូផូស និង អេទីលប៉ារ៉ាស្យុង ទទួលបានលទ្ធផលដ៏ជោគជ័យក្នុងការហាមទាំងស្រុង ឬក៏រិតលក្ខខណ្ឌយ៉ាងតឹងរឹងនូវការប្រើថ្នាំពុលកសិកម្មទាំងនេះ ។ អង្គការនេះ ក៏ចូលរួមផងដែរក្នុងយុទ្ធនាការប្រឆាំងនឹងសរីរាង្គបំលាស់ប្តូរសែន(GMOs) និងចូលរួមក្នុងចលនាមហាជនដើម្បីកសិកម្មអេកូឡូស៊ី និងអធិបតេយ្យភាពស្បៀង ។ អង្គការ PAN-Philippines ជំរុញការតាមដានសកម្មភាពថ្នាំពុលកសិកម្មក្នុងសហគមន៍ (CPAM)ដែលជាការស្រាវជ្រាវ និងឧបករណ៍មួយដើម្បីការពារសហគមន៍ពីឥទ្ធិពលមិនល្អរបស់ថ្នាំពុលកសិកម្ម និងគីមីកសិកម្មដទៃទៀត ។ សំរាប់ជាពតិមានបន្ថែមសូមបើកមើល http://wordpress.com/tag/pesticide-action-network-philippines/ ។

អង្គការ GAIA ជាសម្ពន្ធ័ភាពរួមនៃក្រុមយកចិត្តទុកដាក់ប្រជាជន បានធ្វើការជូនចំពោះចលនាសកម្មភាពប្រជាជន ប្រឆាំងនឹងការរីករាលដាលនៃឡដុតរំលាយ និងបច្ចេកវិជ្ជាបំពុលផ្សេងទៀត និង បង្កើតចលនារកដំណោះស្រាយបរិស្ថាន និងសង្គម ពីបញ្ហាកាកសំណល់ និងវិបត្តិអាកាសធាតុ ។

ការិយាល័យ GAIA ស្ថិតនៅទីក្រុង ម៉ានីល មានតួនាទីជាស្នូលបំរើតំរូវការរបស់សមាជិកនៅអាស៊ី ជាពិសេសការផ្តល់ពតិមាន និងយុទ្ធនាការបញ្ឈប់ការរីកសាយនៃឧស្ម័នផ្ទះកញ្ចក់ និង បច្ចេកវិជ្ជាបោះចោលផលិតផល POPs ។ ម្យ៉ាងទៀត អង្គការនេះ មានតួនាទីគាំទ្រ លើកទឹកចិត្តដល់សង្គមស៊ីវិល ចូលរួមក្នុងការងារ បញ្ហាសុវត្ថិភាពសារធាតុគីមី ។ សំរាប់ជាពតិមានបន្ថែមអំពី GAIA សូមបើកមើល http://www.no-burn.org/ ។

## ១.៣ IPEP: សេចក្តីព្យាយាមថ្នាក់សាកល ជាតិ និង តំបន់

មានគម្រោងរួមមួយដែលមានបំណងរៀបចំ និងកសាងសមត្ថភាព NGOs ដើម្បីចូលរួមប្រកបដោយប្រសិទ្ធិភាពក្នុងការអនុវត្តន៍អនុសញ្ញាស្តីពី POPs នៅថ្នាក់ជាតិ ។ គម្រោង IPEP មានគោលបំណង ៣ :

- ធ្វើការប្រឹងប្រែងច្បាស់លាស់ ក្នុងបំណងជួយប្រទេសស្ថិតនៅភាគខាងត្បូងពិភពលោករៀបចំអនុវត្ត សន្ធិសញ្ញា POPS
- បង្កើនជំនាញ និងចំណេះដឹង ដល់អង្គការតូច និងមធ្យម ដើម្បីជួយបង្កើនសមត្ថភាពពួកគេ ទៅជាអ្នកពាក់ពន្ធ័ដែលមានប្រសិទ្ធិភាពក្នុងការអនុវត្តអនុសញ្ញា ក្នុងប្រទេសស្ថិតនៅភាគខាងត្បូងសាកលលោក និង
- បង្កើតការសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ជាតិ ចំពោះអង្គការសុខភាព និងបរិស្ថាន ដែលទាក់ទងនឹង POPs និង សារធាតុគីមីពុលទំរង់ផ្សេងទៀត។

អង្គការតូច និងមធ្យមជាង ១៧៥ អង្គការក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសមានសេដ្ឋកិច្ចអន្តរភាព ចំនួន ៦៥ បានអនុវត្តន៍សកម្មភាពជាង ២៥០ គម្រោង។ លើសពីនេះ គេបានបង្កើត ស្ទូលជួយសម្រួលថ្នាក់តំបន់ចំនួន ៨ (សូមមើល គេហទំព័ររបស់ IPEP - www.ipen.org/ipepweb1)។

អង្គការ PAN-Philippines និង GAIA (ជាសហស្ទូល) បានសម្របសម្រួលអង្គការចំនួន ៣៦ នៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ចំនួន ៥ (ហើយចំនួន ២ ប្រទេសទៀតនៅអាស៊ីបូព៌ា និងអាស៊ីខាងត្បូង) ឱ្យបានអនុវត្ត ២៣ គម្រោង។

## ១.៤ បណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ (IPEN)

ចាប់តាំងពីឆ្នាំ ១៩៩៨ បណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ (ជាបណ្តាញការងារពិភពលោក ដែលមាន អង្គការពាក់ពន្ធ័នឹងប្រជាជន អង្គការសុខភាព និងអង្គការបរិស្ថាន ច្រើនជាង ៦០០អង្គការ) បានធ្វើការលុបបំបាត់សារធាតុគីមីពុល" អាក្រក់ទាំង ១២ " តាមមូលដ្ឋានសមធមិសង្គមយ៉ាងឆាប់រហ័ស ។ សារធាតុគីមីពុលទាំងនេះបានកំណត់ជាការងារចំបងក្នុងអនុសញ្ញាស្តុកខូម ស្តីពី សារធាតុសរីរាង្គបំពុលមិនងាយបំបែកធាតុ ។ អនុសញ្ញាស្តុកខូមជាសន្ធិសញ្ញា ចងភ្ជាប់ច្បាប់ជាសាកលដំបូង ដែលត្រួតពិនិត្យការផលិត និងការបញ្ចេញ សារធាតុគីមីពុល ។ ក្នុងគោលបំណងកាត់បន្ថយ និងលុបបំបាត់សារធាតុគីមីពុលដែលធ្វើឱ្យអន្តរាយ គេចាប់ផ្តើមដោយរៀបចំបញ្ជីដំបូងដែលមាន POPs[1] ចំនួន ១២ មុខ ។ POPs ធ្វើដំណើរយ៉ាងឆ្ងាយ និងស្ថិតនៅយូរក្នុងបរិស្ថាន ។ វាប្រមូលផ្តុំនៅ ក្នុងច្រវ៉ាក់ចំណីអាហារ រួមទាំងខ្លួនមនុស្សយើងដែរ ។ POPs អាចបំផ្លាញប្រពន្ធ័តំណពូជ ប្រពន្ធ័ប្រសាទ និង ប្រពន្ធ័ភាពស៊ាំ ព្រមទាំងបង្កឱ្យមានបញ្ហាក្នុងការលូតលាស់ និង ជំងឺមហារីក។

នៅឆ្នាំ ២០០៦ IPEN បានយល់ព្រមលើសេចក្តីថ្លែងការស្តីពី អនាគតគ្មានជាតិពុល (http://www. ipen.org/ ipenweb/library/ipendocuments/ipenddeng.pdf) របស់ខ្លួន ហើយបានពង្រីកការសន្យាថា :

*" ដើម្បីការងារ និងសម្រេចលទ្ធផលនៅឆ្នាំ ២០២០ នូវ អនាគតគ្មានជាតិពុល ដែលការផលិត និង ការប្រើប្រាស់សារធាតុគីមីទាំងអស់តាមមាគាំមួយដែលលុបបំបាត់ឥទ្ធិពលមិនល្អលើសុខភាពមនុស្ស និងបរិស្ថាន ហើយ*

[1] Aldrin, endrin, chlordane, DDT, dieldrin, dioxins and furans, endrin, heptachlor, hexachlorobenzene, mirex, PCBs និង toxaphene

*សារធាតុសរីរាង្គពុលមិនងាយបំបែកធាតុ និងសារធាតុគីមីដែលទាក់ទងជាច្រើនទៀត មិនធ្វើឱ្យកខ្វក់យូរដល់បរិស្ថាន សហគម និងសាកលលោករបស់យើង ព្រមទាំងមិនប្រលាក់ប្រលូកដល់សហគមន៍យើង ចំណីអាហារយើង រូបកាយរបស់យើង ឬរូបកាយកូនរបស់យើង និងជំនាន់ក្រោយរបស់យើង"* ។

តាមបេសកកម្មរបស់ IPEN បានផ្តោតសំខាន់លើការសន្ទនាជាមួយ NGOs ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសសេដ្ឋកិច្ចអន្តរភាព តាមការពិភាក្សាគោលនយោបាយថ្នាក់អន្តរជាតិ និងជាតិ ដូចជា ជំរុញការបង្កើនសមត្ថភាព និងសកម្មភាពបង្កើនការយល់ដឹង ដល់ NGOs នៅថ្នាក់មូលដ្ឋាន ។

## ១.៥ ការស្ទាបស្ទង់ថ្នាក់តំបន់

ការតាមដានសកម្មភាពជាង ២៩០ ដែលបានអនុវត្តដោយគម្រោង IPEP ត្រូវបានលេខាធិការដ្ឋាន IPEN និងស្នូលតំបន់ទាំង៨[២] បញ្ចូលទៅក្នុងយុទ្ធសាស្ត្រសកម្មភាពថ្នាក់តំបន់ដើម្បីប្រមូលពតិមានពី NGOs ដែលធ្វើការលើរឿងសុវត្ថិភាពសារធាតុគីមី ជាចំណុចសំខាន់មួយនៅក្នុងគម្រោងអាទិភាព តម្រូវការ សមត្ថភាព និងឱកាសរបស់ NGOs តាមទស្សនវិស័យតំបន់ ។ គំរូនៃការស្ទាបស្ទង់រួមមួយបានបង្កើតឡើងដោយ ស្នូលតំបន់ទាំងអស់របស់ IPEN និងលេខាធិការដ្ឋាន ហើយបានបកប្រែពីភាសាអង់គ្លេសទៅជាភាសា អារ៉ាប់ បារាំង រូស្សី និង អេស្បាញ ដើម្បី ផ្សព្វផ្សាយដល់គ្រប់បណ្តាញកាងារនៅតំបន់ទាំងអស់ ។ នៅពេលដំណើរការស្ទាបស្ទង់ ស្នូលតំបន់នីមួយៗបានបង្កើតបញ្ជីអាសយដ្ឋានអ៊ីម៉ែល និងទិន្នន័យទាក់ទងនឹង NGOs សំរាប់ជំរុញបណ្តាញការងារថ្នាក់តំបន់ ។ ជាសរុបគេបានស្ទាបស្ទង់ NGOs ចំនួន ២០៨ អង្គការនៅក្នុងប្រទេសចំនួន ៨២ ក្នុងពិភពលោក ។

ការប៉ាន់ប្រមាណនៅតំបន់អាស៊ីអាគ្នេយ៍បានស្ទាបស្ទង់ NGOs ចំនួន ២៤ អង្គការនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និង វៀតណាម រួមទាំងប្រទេសចិន ឥណ្ឌា និង ស្រីលង្កា ផងដែរ។ ក្រុមមួយនៃអ្នកផ្តល់ពតិមានផ្តោតលើបញ្ហាថ្នាំពុល និងជំរុញកសិកម្មនិរន្តរភាព រួមទាំងជំរើសផ្សេងៗតាមគោលការណ៍ធម្មជាតិមិនប្រើប្រាស់សារធាតុគីមីថ្នាំពុលកសិកម្ម ។ ក្រុមផ្សេងទៀត ធ្វើការលើបញ្ហាបំពុលដែលពាក់ពន្ធ័នឹង ការបំពុល នៃកាកសំណល់ទីក្រុង ឧស្សាហកម្ម និងមន្ទីរពេទ្យ និងពីឧបករណ៍ចោលសំរាម ដូចជា គំនរសំរាម ទីវាលចាក់សំរាម និងឡដុតរំលាយ ។

អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ បានផ្តល់ពតិមានដល់ការប៉ាន់ប្រមាណតំបន់ ដោយសារការចូលរួមជាមួយបណ្តាញការងារលុបបំបាត់ POPs អន្តរជាតិ និងឬ គម្រោងលុបបំបាត់ POPs អន្តរជាតិ ឬមានបទពិសោធន៍

[២] ស្នូលតំបន់ទាំង៨មាន: អាហ្វ្រិកនិយាយភាសាអង់គ្លេស( ការងារជាភាសាអង់គ្លេស និងគីស្វាហ៊ីលី) អឺរ៉ុបកណ្តាល ( ការងារជាភាសាអង់គ្លេស) អឺរ៉ូបខាងកើត តំបន់អាស៊ីស្បែកស និងកណ្តាល ( ការងារជាភាសារ៉ូស្សី) អាហ្វ្រិកនិយាយភាសាបារាំង ( ការងារជាភាសាបារាំង) អាមេរិកឡាទីន និង ការីបប៊ីន ( ការងារជាភាសាអេស្បាញ និងអង់គ្លេស) មជ្ឈឹមបូពា ( ការងារជាភាសាអារ៉ាប់) អាស៊ីខាងត្បូង ( ការងារជាភាសាអង់គ្លេស) និង អាស៊ីអាគ្នេយ៍ និងអាស៊ីបូពានិងប៉ាស៊ីហ្វិក ( ការងារជាភាសាអង់គ្លេស) ។

ដែលសហសម្ពន្ធ IPEN តំបន់អាស៊ីអាគ្នេយ៍ (PAN-Philippines និង GAIA)យល់ឃើញថា មានសមត្ថភាពយល់ដឹងច្រើន និងត្រឹមត្រូវ ។ ភាគច្រើននៃអង្គការដែលបានស្ទាបស្ទង់ ផ្តោតសកម្មភាពលើថ្នាក់មូលដ្ឋាន និងជាតិ ។ ហើយអង្គការ ចំនួន ១៦ បានអនុវត្តសកម្មភាពរបស់គម្រោង IPEN បានពេញលេញ ។

## ២. លទ្ធផលស្ទាបស្ទង់

## ២.១ សុខភាព និងឥទ្ធិពលសារធាតុគីមី

### ២.១.១ ថ្នាំពុលកសិកម្ម

លទ្ធផលស្ទាបស្ទង់បានបង្ហាញថាអាទិភាពរបស់ក្រុមបណ្តាញសកម្មភាពថ្នាំពុលសកិកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺថ្នាំពុលមានឥទ្ធិពលលើសុខភាពសហគមន៍ និងបញ្ហាស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ និង បញ្ហាបំពុល ។ ក្រុមជាច្រើនដែលបានស្ទាបស្ទង់កំពុងធ្វើការជាមួយប្រជាជន ជាពិសេសសហគមន៍កសិកម្មដែលបាន និងកំពុងទទួលរងឥទ្ធិពលមិនល្អនៃការអនុវត្តកសិកម្មពឹងផ្អែកលើថ្នាំពុលកសិកម្មតាមការផ្សព្វផ្សាយពីក្រុមហ៊ុនគីមីកសិកម្មធំៗនិង រដ្ឋាភិបាល។

បញ្ហាដ៏អាក្រក់នៃការចុះខ្សោយសុខភាព និងបរិស្ថាន ក្នុងប្រទេសពាក់ពន្ធ័នឹងការប្រើប្រាស់គីមីកសិកម្ម បាន និងកំពុងតាស់តឿន NGOs ឱ្យផ្តោតការយកចិត្តទុកដាក់លើបញ្ហាថ្នាំពុល(រួមទាំង POPs) ជាពិសេសការប៉ះពាល់ដល់សហគមន៍ប្រជាជន ស្ត្រី កុមារ កសិករ ប្រជានេសាទ ជនជាតិភាគតិច និងក្រុមអ្នកងាយរងគ្រោះ ។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះក៏បានដឹងដែរថាការចុះខ្សោយសុខភាព និងបរិស្ថានបានកើតឡើងដោយសារគីមីកសិកម្ម មិនអាចដោះស្រាយបាននូវបញ្ហាធំៗដូចជា ការបាត់បង់ដីធ្លី ស្ថានភាពសេដ្ឋកិច្ចកាន់តែអាក្រក់ និង ការឱ្យតម្លៃ សហគមន៍ប្រជាជនកាន់តែតិច ។

### ២.១.២ សំរាម

នៅអាស៊ីអាគ្នេយ៍ ជាពិសេសប្រទេសឧស្សាហកម្មដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីភីន ថៃ និង វៀតណាម កំពុងប្រឈមនឹងការទុកដាក់សំរាម និងបញ្ហាបំពុលដែលកើតឡើងដោយសារ កំណើនចំនួនមនុស្ស ដំណើរ ការឧហ្សាកម្មអាក្រក់ និងសាកលភាវូបនីយកម្មនៃគំរូប្រើប្រាស់តាមបស្ចឹមប្រទេសធ្វើឱ្យបោះចោលនូវវប្បធម៌ ។ ការងារបន្ទាន់របស់ប្រទេសដែលមានផលប៉ះពាល់បញ្ហាសំរាម គឺសម្រាលផលវិបាកនៃការផលិត និងការប្រើប្រាស់ដែលបណ្តាលឱ្យកើតសំរាម។ ពួកគេកំពុងទាក់ទាញឱ្យមានការសាងសងប្រដាប់ដុតសំរាម រួមមាន ឡដុតរំលាយ "សំរាមជា ថាមពល" ។

ចំពោះក្រុម GAIA ក្នុងតំបន់ : NGOs ភាគច្រើនចាត់ជាអាទិភាពបំផុតចំពោះសំរាម គំនរឬកន្លែងចាក់សំរាម និងឡដុតរំលាយ និងការបង្ការឌីអុកស៊ីន និង POPs កើតឡើងដោយអចេតនា ដូចជាឧស្ម័នផ្ទះកញ្ចក់ ។ រឿងនេះ មានការពន្យល់យ៉ាងក្បោះក្បាយដូចជា ១) ការកើនឡើងនូវបរិមាណ និងភាពពុលរបស់សំរាមដែលជាលទ្ធផល

មកពីការលូតលាស់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជឿនលឿន តាមលំនាំផ្លូវនៃសង្គមដែលធ្វើឱ្យវិនាសបរិស្ថាន និងទំនាក់ទំនង។ ២) ការឈ្លានពានទីផ្សារបច្ចេកវិជ្ជាសំរាប់ការចាក់ចោល និងការបំផ្លាញសំរាម ដូចជាកន្លែងចោលសំរាម និងឡដុតរំលាយ ដើម្បីដោះស្រាយកន្លែងដាក់សំរាម និង ៣) ការកើននូវការយកចិត្តទុកដាក់ ជាពិសេសពីចំណោមក្រុមសុខភាពបរិស្ថាន និងយុត្តិធម៌ ដើម្បីបញ្ឈប់ការប្រឡាក់ឌីអុកស៊ីន ពីប្រភពដែលអាចការពារបាន ដូចជា ពី ការដុតរំលាយសំរាម និងពីទីវាលដុតសំរាម ។

ការកង្វល់របស់ NGOs ពីបញ្ហាសំរាម មិនកំណត់តែចំពោះកាកសំណល់រឹងរបស់ទីក្រុងប៉ុណ្ណោះទេ តែគិតទាំងលំហូរសំរាមផ្សេងទៀតដូចជា សំរាមកើតឡើងដោយមន្ទីរពេទ្យ និងឧបករណ៍ព្យាបាលសុខភាព (សំរាមកើតពីការព្យាបាល) និង វាបង្កើតដោយរោងចក្រ និងឧស្សាហកម្ម (កាកសំណល់ឧស្សាហកម្ម ពុល និងគ្រោះថ្នាក់ រួមទាំង កាកសំណល់គ្រឿងអគ្គិសនី) ។

## ២.១.៣ ការសាយភាយ POPs: ឌីអុកស៊ីន និង POPsកើតដោយអចេតនា

លទ្ធផលស្ទាបស្ទង់បានបង្ហាញថា មានការកើនឡើងនូវប្រុងប្រយ័ត្នដើម្បីការពារការបង្ក និងការបញ្ចេញនូវឌីអុកស៊ីន និង POPsកើតដោយអចេតនា ជាពិសេសពីប្រភពដូចជា: ការដុតសំរាមនៅទីវាល រួមមានការដុតកន្លែងចាក់សំរាម ឡដុតរំលាយសំរាម រាប់ទាំងឡរួមសំរាប់ដុតរំលាយសំរាមពីទីក្រុង ការព្យាបាលសុខភាព និង សំរាមប្រកបដោយគ្រោះថ្នាក់។

គម្រោង IPEP នៅអាស៊ីអាគ្នេយ៍បានគាំទ្រគម្រោងរបស់NGOs ដោះស្រាយការសាយភាយ POPs ពីឡដុតរំលាយ ដូចជាឧបករណ៍សំរាប់ដុតរំលាយសំរាមទីក្រុង នៅភូកេត និងសាមួយ ប្រទេសថៃ និង សំរាមពីការព្យាបាលសុខភាពនៅទីក្រុងទ្រីសម៉ាទី ប្រទេសហ្វីលីភីន ។ គម្រោង IPEP បានឧបត្ថម្ភដល់គម្រោងដទៃទៀតក្នុងប្រទេសម៉ាឡេស៊ី ទាក់ទងនឹងការសិក្សាស្រាវជ្រាវនៅសហគមន៍ ការអភិវឌ្ឍន៍ជំរើសគោលនយោបាយផ្សេងៗ និងការបង្កើនការយល់ដឹង សំរាប់គម្រោងឡដុតរំលាយសំរាមដ៏ធំមួយ ។

កង្វះខាតដ៏ចំបងក្នុងការកំណត់បញ្ហាជាអាទិភាពរួមមាន: ១) កង្វះខាតច្បាប់ជាតិ ដែលគាំទ្រការកាត់បន្ថយសំរាម និងជាតិពុលនៅនឹងប្រភព ផលិតកម្មស្អាត ការទទួលខុសត្រូវរបស់ផលិតករ ការគ្រប់គ្រងសំរាមតាមគោលការណ៍បរិស្ថាន ព្រមទាំងគោលការណ៍ និងគោលនយោបាយ បង្ការការធ្វើឱ្យមានសំរាម និងការកខ្វក់។ ២)សង្គមស៊ីវិលនៅខ្សោយក្នុងការពិនិត្យមើលក្រុមហ៊ុនលក់ដូរ និងការផ្សព្វផ្សាយបច្ចេកវិជ្ជាបោះចោលសំរាមដែលអាច បង្កើតឌីអុកស៊ីន និង ៣) កង្វះខាតបច្ចេកវិជ្ជារឹងមាំ និងគ្រប់គ្រាន់ដើម្បីសុវត្ថិភាពចោលនូវសំរាមប្រកបដោយគ្រោះថ្នាក់។

### ២.១.៤ សម័យការរីកចំរើនសេដ្ឋកិច្ច និងសារធាតុគីមីប្រកបដោយសុវត្ថិភាព

ការសិក្សាថ្នាក់តំបន់របស់ IPEN បានបង្ហាញថា សារៈសំខាន់នៃភាពរីកចំរើនដែលផ្តល់ដោយក្រុមសង្គមស៊ីវិលចំពោះបញ្ហាសំខាន់ដូចគ្នា ( តាមលក្ខណៈតំបន់ ) រួមមាន ១) ការកាត់បន្ថយពន្ធដល់សូន្យពីសារធាតុដែលហាម និងត្រួតពិនិត្យជាសាកលនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេរភាគី ជាពិសេស រវាងប្រទេសជប៉ុន និងប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍( អាស៊ាន) ។ ២) វិបត្តិនៃការចោលសំរាម សំរាប់ទំនិញដែលបានប្រើហើយ ដូចជា សំរាមគ្រឿងអគ្គិសនី នៅប្រទេសឧស្សាហកម្មជឿនលឿន និង ៣) បញ្ហាសុខភាព និងសុវត្ថិភាពទាក់ទងនឹងពាណិជ្ជកម្មចំណីអាហារ និងកសិកម្ម ផលិតផលគ្រឿងសំអាង ថ្នាំពេទ្យ និងប្រដាប់ក្មេងលេង ។

ដោយឡែកកិច្ចព្រមព្រៀងជាដៃគូរសេដ្ឋកិច្ច ជាមួយប្រទេសអាស៊ីអាគ្នេយ៍នីមួយៗ និង កិច្ចព្រព្រៀងពាណិជ្ជកម្មសេរីទូលំទូលាយរវាងជប៉ុន និងអាស៊ាន ផ្តល់ឱកាសដល់ក្រុមសុខភាពបរិស្ថាន និងយុត្តិធមិ ជាសម្លេងប្រឆាំងនឹងការចាក់ចោលសំរាមប្រកបដោយជាតិពុល និងគ្រោះថ្នាក់ រួមទាំងកាកសំណល់គ្រឿងអគ្គិសនី ដូចជា ការនាំចេញបច្ចេកវីជ្ជា និងឧស្សាកម្មកខ្វក់ទៅប្រទេសកំពុងអភិវឌ្ឍន៍ ។ កិច្ចព្រមព្រៀងជាដៃគូរសេដ្ឋកិច្ចដែលអាចមានវាទប្បដិវាទ ផ្តល់ឱកាសផងដែរដល់ក្រុមសុខភាពប្រជាជន និង បរិស្ថាន ដើម្បីសន្ទនា និងរួមកម្លាំងជាមួយក្រុម និងចលនាស្វែងរកការជួយសង្គ្រោះ និងទំនាក់ទំនងស្មើភាពគ្នារវាងជាតិ និងជាតិ ដូចជាការបង្ហាញបទពិសោធន៍របស់សមាជិក IPEN នៅក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីភីន និង ថៃ ។

## ២.២ គោលការណ៍ ឧបករណ៍ និងយុទ្ធសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាល

### ២.២.១ ការបង្កើនការយល់ដឹង

ក្នុងការឆ្លើយតបនឹង POPs និងសារធាតុគីមីដែលពាក់ពន្ធ័នោះ មានសកម្មភាព NGO លេចឡើងយ៉ាងច្រើននៅក្នុងតំបន់ រួមមាន ការស្រាវជ្រាវ ការផលិត និងចែកចាយសម្ភារៈពត៌មាន ការរៀបចំសេចក្តីថ្លែងការជាសាធារណៈ ការរៀបចំព្រឹត្តិការណ៍តាមប្រពន្ធ័ផ្សព្វផ្សាយ សិក្ខាសាលា និងការបណ្តុះបណ្តាលបង្កើនការយល់ដឹង ការងារអភិវឌ្ឍន៍ គាំទ្រ និងបញ្ចុះបញ្ចូលគោលនយោបាយ ការតាមដាន ការចុះផ្ទាល់ដល់មូលដ្ឋាន និងការចលនាសហគមន៍។

គម្រោង និងសកម្មភាពបង្កើនការយល់ដឹងរបស់ NGOs ក្នុងតំបន់បានរៀបចំ ឧបករណ៏ផ្សេងៗដើម្បីផ្សាយពត៌មាន និងចំណេះដឹង ដូចជា ចុះផ្ទាល់ដល់មូលដ្ឋានរបស់ប្រជាជន និងក្រុមពាក់ពន្ធ័ធ្វើការរួមគ្នាដូចជា សិក្ខាសាលា បណ្តុះបណ្តាល ពិភាក្សាជាក្រុម បញ្ចាំងវិដេអូ ចុះផ្សាយអត្ថបទតាមព្រឹត្តិបត្រ័ បណ្ណ័ពត៌មាន កាសែត ទស្សនាវដ្តី និងឧបករណ៏បណ្តាញមូលដ្ឋាននានា ។ គម្រោង IPEP ក៏មានខ្សែវិដេអូស្តីពី " អេលីសរស់នៅទីនេះ" បានផ្តល់ជាគំនិតថ្មីមួយដល់ការតស៊ូរបស់សហគមន៍ប្រឆាំងនឹងសំណើបង្កើតឡដុតរំលាយ ហើយវាបានបង្កើនការយល់ដឹងពីការដុតរំលាយ និងបញ្ហា POPs ព្រមទាំងជំរុញទឹកចិត្តអ្នករស់ក្នុងសហគមន៍មានសម្លេងរឹងមាំ ។

ការស្ទាបស្ទង់បានបង្ហាញថា NGOs ឱ្យតម្លៃតួនាទីរបស់ប្រពន្ធ័ផ្សព្វផ្សាយក្នុងការផ្តល់ពត៌មានជាសាធារណៈ ពីបញ្ហាសុវត្ថិភាពសារធាតុគីមី ដូចជា ណែនាំការពិភាក្សា និងសកម្មភាពដើម្បីដាក់សម្ពាធដល់បញ្ហាដែលទាក់ទង ។

NGOs នៅប្រទេសហ្វីលីភីន បានប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន បង្កើតពត៌មាន និងសេចក្តីថ្លែងការណ៍ និងរៀបចំបង្កើតសកម្មភាពផ្ទាល់ ឬសកម្មភាពទំនាក់ទំនងផ្ទាល់ និយាយចំៗ លើបញ្ហាសុខភាព បរិស្ថាន និងយុត្តិធម៌សង្គម ។ អ្នកខ្លះរួមជាក្រុមជាមួយជនល្បីល្បាញក្នុងវិស័យសិល្បៈកំសាន្ត កីឡា និងនយោបាយ ដើម្បីបង្កើនការដឹងឮកាន់តែទូលំទូលាយ ។ អង្គការមួយ(សហពលកម្មសំរាមបរិស្ថាន)បានប្រើកាសែតសន្លឹកធំ កាសែតសន្លឹកតូច និងទស្សនាវដ្តី ផ្សាយដំណឹងជូនដល់មហាជន រួមទាំងអ្នកនយោបាយ ពីរឿងសំរាម ឌីអុកស៊ីន ភីស៊ីប៊ី និង POPs កើតដោយអចេតនា ព្រមទាំងសារធាតុគីមីដែលពាកពន្ធ័ ដូចជាបារ៉តនៅក្នុងអំពូលភ្លើង សំណ និងផ្តាឡាតនៅក្នុងប្រដាប់ក្មេងលេង ។

NGOs មួយនៅប្រទេសម៉ាឡេស៊ី ឈ្មោះ សមាគមអតិថិជនប៉េណាំង បានចាត់ចែងផ្តល់ពត៌មានស្តីពី POPs និង សារធាតុគីមីគ្រោះថ្នាក់ផ្សេងទៀត តាមរយៈពត៌មានអតិថិជន កូនសៀវភៅ មគ្គុទេសវ៉ៃឆ្លាត និង ការបោះពុម្ពដែលមានប្រជាប្រិយភាព ជាភាសាចិន អង់គ្លេស ម៉ាឡេ និងតាមីល ដើម្បីឱ្យបានទៅដល់គ្រប់ក្រុមមនុស្សទាំងអស់ ។

នៅកម្ពុជាមានប្រពន្ធ័ផ្សាយពត៌មានជាតិ បានផ្តល់សកម្មភាពបង្កើតការយល់ដឹងជាសាធារណៈ ពីបញ្ហា POPs ថ្នាំកសិកម្ម និងជំរើសផ្សេងៗប្រកបដោយនិរន្តរភាព របស់មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ។ ក្រុមការងាររបស់អង្គការសេដាក បានរៀបចំវេទិកាសិក្ខាសាលាស្តីពីបញ្ហា POPs ហើយបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈវិទ្យុ និង ទូរទស្សន៍ក្នុងស្រុកជាច្រើន ។

ការស្ទាបស្ទង់បានបង្ហាញថាមាន NGOs ភាគច្រើនដែលមាន គេហទំព័ររបស់ខ្លួន បានប្រើប្រពន្ធ័អ៊ិនធើណេតជាយុទ្ធនាការ ផ្តល់ជាមតិយោបល់ និងសកម្មភាព ។ល ។

## ២.២.២ បណ្តាញការងាររបស់អង្គការមិនមែនរដ្ឋាភិបាល

ភាគច្រើននៃអ្នកផ្តល់ពត៌មានជាសមាជិកសកម្មរបស់ GAIA IPEN និង PAN ហើយ ខ្លះធ្វើការក្នុងបណ្តាញការងារផ្សេងទៀត ដូចជា BAN និង HCWH លើបញ្ហាជាក់លាក់ ។ កំរិតនៃការចូលរួមរបស់ NGOក្នុងបណ្តាញការងារមានអត្ថន័យយ៉ាងធំធេង តាមតំរូវការរួមរបស់ក្រុមថ្នាក់មូលដ្ឋាន ឬជាតិ ទទួលទំនាក់ទំនងពីថ្នាក់តំបន់ ឬអន្តរជាតិ និង ត្រូវបានគាំទ្រលើបញ្ហាស្នូល ដែលពួកគេកំពុងធ្វើការ ដូចជា ផ្លាស់ប្តូរពត៌មាន យុទ្ធនាការគាំទ្រ ជំនួយការបច្ចេកទេស និងវិទ្យាសាស្ត្រ ។ល ។ ការគាំទ្រពីអន្តរជាតិ និង តំបន់ ក៏ផ្តល់ថាមពល ឬអំណាចបន្ថែម ដល់ក្រុមមូលដ្ឋាន ឱ្យពួកគេអាចសន្ទនា បញ្ចុះបញ្ចូល អ្នកនយោបាយជាតិ ។

IPEN តាម IPEP បានចែករំលែកដល់ NGOs នូវធនធាន ដើម្បីធ្វើការសិក្សា និងគម្រោងរយៈពេលខ្លី ដូចជារបាយការណ៍ស្ថានភាពប្រទេស របាយការណ៍ពីកន្លែងគ្រោះថ្នាក់ និងសកម្មភាពផ្សេងៗតាមប្រទេស ។ ភាគច្រើន

NGOs ដែលបានអនុវត្ត IPEP បានទទួលការគាំទ្របច្ចេកទេស និងការណែនាំ ពីអ្នកជំនាញការ និង សកម្មជនរបស់ IPEN និង បណ្តាញការងារសម្ពន្ធ័មិត្ត ។

គួរឱ្យកត់សំគាល់ដែរថា អ្នកផ្តល់ពតិមានជាច្រើនបានរួបរួម ជាមួយសហគមជាតិ ធ្វើការដោះស្រាយបញ្ហា សេដ្ឋកិច្ចសង្គម នយោបាយ សុខភាព បរិស្ថាន និងយុត្តិធមិសង្គម ។ សហគមជាតិទាំងនេះមានរាយនាមដូចខាងក្រោម ផ្តល់អ្នកផ្តល់ពតិមានយុត្តាធិការ សំរាប់ការគាំទ្រ និង សំរាប់ធានាការទទួលសាល់ និងការគាំទ្រនៅថ្នាក់មូលដ្ឋាន ។

***កម្ពុជា*** : វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ( មានអង្គការជាតិ និងអន្តរជាតិ ចំនួន ៧៨ ជាសមាជិក ពេញសិទ្ធិ ចំនួន ២សមាជិកជាដៃគូ និង ចំនួន ១១ ក្រុម មិនមែនជាសមាជិក)

***ឥណ្ឌូនេស៊ី:*** វេទិកាប្រជាជនឥណ្ឌូនេស៊ី ( មានច្រើនជាង ៤0 អង្គការសង្គមស៊ីវិល តំណាងក្រុមធំៗ ចំនួន ៦ : កសិករ កម្មករ ជនជាតិភាគតិច ស្រ្តី យុវជន និង NGOs) វេទិកាឥណ្ឌូនេស៊ីពីសំរាម ( អង្គការដៃគូច្រើន រួមទាំងភ្នាក់ងាររដ្ឋាភិបាល និង NGOs) JALA-Sampah ឬ បណ្តាញការងារសំរាម ( មាន ២៥ ក្រុមជា សមាជិក)

***ម៉ាឡេស៊ី:*** អង្គការមិនមែនរដ្ឋាភិបាលបរិស្ថានម៉ាឡេស៊ី ឬ MENGO ( មាន ១៩ NGOs បរិស្ថាន)

***ហ្វីលីពីន:*** សហពន្ធ័សំរាមបរិស្ថាន ( មានសមាជិក ៧៥ ក្រុម) បណ្តាញការងារប្រជាជន ដើម្បីបរិស្ថាន ( មាន ២៨ ផ្នែក ក្រុមតំបន់ និង NGOs) ប្រឆាំងគីមីកសិកម្មរបស់ TNCs ( មាន ៥២ អង្គការ និងស្ថាប័ន)

ការអនុវត្តន៏គម្រោង IPEP ជាពិសេស នៅប្រទេសថៃ បង្កើតបានបណ្តាញការងារថៃលុបបំបាត់ POPs ហៅកាត់ថា ThaiPEN ( មាន ៧ ក្រុម)ដែលផ្តល់ការសម្របសម្រួលសំរាប់ការចែករំលែកពតិមាន សំរាប់បង្កើន សមត្ថភាព និង សំរាប់ធ្វើការអភិវឌ្ឍជំហរ និងសកម្មភាព សង្គមស៊ីវិលលើបញ្ហា POPs ។

## ២.២.៣ ការចូលរួមនយោបាយ: ការចូលរួមពីអន្តរជាតិ និង ជាតិ

ជាទូទៅ ការស្ទាបស្ទង់បានបង្ហាញថា មានការចូលរួមរបស់ NGOs នៅក្នុងការអភិវឌ្ឍន៏គោលនយោបាយ សារធាតុគីមីជាតិនៅអាស៊ីអាគ្នេយ៏ ។ នៅពេលមានសកម្មភាពពីមូលដ្ឋានជាច្រើនលើបញ្ហាសារធាតុគីមី និងជាតិពុល នោះ គឺមាន NGOs តិចណាស់បានចូលប្រលូកយ៉ាងទៀងទាត់ក្នុងដំណើរការថ្នាក់ជាតិ ដែលជាទូទៅមិនមានសមត្ថភាព និងប្រសិទ្ធិភាពក្នុងការជំរុញដល់ការចូលរួមរបស់សង្គមស៊ីវិលទេ ។ នេះអាចត្រូវបានគេសន្នត់ថា
១) NGOs ខ្វះសមត្ថភាពដើម្បីចូលរួមគ្រប់កិច្ចប្រជុំ និងកិច្ចពិគ្រោះយោបល់ពីគោលនយោបាយថ្នាក់ជាតិ សំខាន់ៗ ២) កង្វះខាតភាពបើកចំហរដល់ការចូលរួមរបស់សង្គមស៊ីវិលក្នុងដំណើរការនយោបាយ ។ ៣) រឿងរ៉ាវនយោបាយ

សំខាន់ៗ ត្រូវបានពិភាក្សា និងសម្រេចនៅតែទីក្រុង ហើយ NGOs មួយចំនួននៅឆ្ងាយ ខ្វះជំនួយសំរាប់ការធ្វើដំណើរ និង ស្នាក់នៅ ដើម្បីមកទីក្រុងចូលរួម ។

តួយ៉ាង នៃការចូលរួមខ្លះទៀត រួមទាំង សហស្ទូល IPEN អាស៊ីអាគ្នេយ៍ បានចូលរួមយ៉ាងប៉ិនប្រសប់ ក្នុងគណៈកម្មាធិការជាតិសំរាប់ផែនការអនុវត្តជាតិអនុសញ្ញាស្តុកខូមស្តីពី POPs របស់ប្រទេសហ្វីលីភីន ហើយក្រុមដទៃទៀតបានចូលរួមយ៉ាងសកម្មក្នុងការងារនយោបាយសារធាតុគីមីនៅថ្នាក់មូលដ្ឋាន ដូចជា ការតស៊ូមតិទទួលបានជោគជ័យ ដោយរដ្ឋាភិបាលមូលដ្ឋានមីនដានាវធ្វើការហាមបាញ់ថ្នាំពុលកសិកម្មតាមយន្តហោះ ។

នៅកម្ពុជា មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សហការជាមួយក្រសួងកសិកម្ម ធ្វើការកាត់បន្ថយថ្នាំពុលកសិកម្ម និងអនុវត្តវិធានការចម្រុះគ្រប់គ្រងដំណាំ។ នៅប្រទេសម៉ាឡេស៊ី សមាគមអតិថិជនប៉េណាំងជួយដល់នាយកដ្ឋានបរិស្ថាននៃក្រសួងធនធានធម្មជាតិ និងបរិស្ថាន ធ្វើការរៀបចំផែនការអនុវត្តជាតិសំរាប់គ្រប់គ្រង POPs។ នៅប្រទេសថៃ ក្នុងភាពជាអ្នកដឹកនាំ ThaiPEN បានធ្វើយុទ្ធនាការដើម្បីបណ្តុញការងារឧហ្សាហកម្មតាមជំរើសផ្សេងៗ និង Greenpeace អាស៊ីអាគ្នេយ៍ បានស្នើការពន្យល់ជូនដល់ក្រុមប្រឹក្សាត្រួតពិនិត្យការបំពុលនៃមជ្ឈមណ្ឌលជាតិសកម្មភាព POPs។ នៅឥណ្ឌា ថាណាល ដើរតួរក្នុងយុទ្ធនាការនៅរដ្ឋកេរ៉ាឡា ទទួលបាននូវការហាមថ្នាំពុលកសិកម្មក្រុមអ័រហ្គាណូក្លរីនដែលមានពុលខ្លាំង ឈ្មោះ អង់ដូស៊ុលហ្វាន ។

NGOs ខ្លះបានចូលរួមជាមួយនាយកដ្ឋានរដ្ឋាភិបាលដែលពាក់ពន្ធ័ជាច្រើន ។ សហស្ទូលរបស់ IPEN អាស៊ីអាគ្នេយ៍ បានអញ្ជើញពីមជ្ឈមណ្ឌលសកម្មភាពជាតិសំរាប់អនុសញ្ញាស្តុកខូម និងយុទ្ធសាស្ត្រឆ្ពោះទៅការគ្រប់គ្រងសារធាតុគីមីអន្តរជាតិ ឱ្យចូលរួមក្នុងការប្រជុំជាច្រើន ដែលគេចាត់ចែងតួនាទី ជាអ្នកឃ្លាំមើលដំណើរការគ្រប់គ្រងរបស់មន្ត្រីរដ្ឋាភិបាល និងតំណាងឧស្សាហកម្ម។ គួរឱ្យកត់សំគាល់ដែរថា ប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើន ប្រសិនបើមានយន្តការនៃការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈលើបញ្ហា POPs និងសុវត្ថិភាពសារធាតុគីមី គឺគ្រាន់តែសំរាប់ករណីពិសេសប៉ុណ្ណោះនិង មិនមានឋានៈពេញលេញ ជា NGOsពាក់ពន្ធ័ប្រកបសក្តានុពលឡើយ ។

NGOs ខ្លះមានភាពជោគជ័យច្រើនក្នុងការជំរុញ អ្នកនយោបាយ និង មន្ត្រីរដ្ឋាភិបាល តាមរយៈរបាយការណ៍តាមដានរបស់គេបានជួយទ្រទ្រង់ សុខភាពសាធារណៈ និងបរិស្ថាន ដែលកើតឡើងដោយការស្រាវជ្រាវយ៉ាងល្អិតល្អន់ និង ការផ្តល់យោបល់ដល់អ្នកធ្វើការសម្រេច តាមរយៈការបោះពុម្ព ផ្សព្វផ្សាយ និងប្រពន្ធ័ពតិមានផ្សេងៗ ថែមទាំងមានការតស៊ូអប់រំ និងចលនា សហគមន៏ និងដៃគូរពាក់ពន្ធ័ផង។

ការស្ទាបស្ទង់បង្ហាញថាមាន NGOs ខ្លះ នៅក្នុងតំបន់សម្រេចបានជោគជ័យលើប្រសិទ្ធភាពច្បាប់ និងគោលនយោបាយដែលមានឥទ្ធិពលចំពោះសុខភាព និងបរិស្ថានរបស់សហគម៏ ។ ឆ្នាំនេះក្រុមសង្គមស៊ីវិលនៅប្រទេសម៉ាឡេស៊ី បានរៀបចំពិធីការលុបចោលគម្រោងឡដុតរំលាយដ៏ធំមួយ និងប្រានចោលនូវឧបករណ៏កែច្នៃសំរាមជាឋាមពល ដែលខូច នៅរដ្ឋ សេឡានហ្គរ។ នៅប្រទេសហ្វីលីភីន NGOsសុខភាពសាធារណៈ និងបរិស្ថាន រួមគ្នាជាមួយក្រុម និងចលនាសង្គមផ្សេងៗ បង្កើតជាសហពលកម្មក្រុមប្រឹក្សាប្រជាជន ដោយបង្ខិតបង្ខំមុខងាររបស់ប្រធាន

ផ្ទេរជូនព្រឹទ្ធសភា នៃកិច្ចព្រមព្រៀងដៃគូរសេដ្ឋកិច្ចជប៉ុន-ហ្វីលីពីន(JPEPA)ដែលមានវិវាទគ្នា ឱ្យធ្វើការពិនិត្យសើរើ និងសច្ចាប័ន បន្ទាប់ពីនាំមនុស្ស ៩នាក់ ដែលបានទទួលដំណឹងថាគួរឱ្យជឿ អ្នកប្រឆាំងនៃកិច្ចសន្យាបានឈ្នះ។ នៅប្រទេសឥណ្ឌា គម្រោងសំរាមសូន្យនៅកូវ៉ាឡាម បានរកសេចក្តីដកស្រង់នៅមូលដ្ឋាន និងអន្តរជាតិ បង្កើតជាកម្មវិធីគំរូមួយដែលផ្តោតលើមធ្យោបាយថ្មីៗ ក្នុងការកាត់បន្ថយសំរាម និងការពារបរិស្ថាន ហើយផ្តល់នូវជីវភាពរស់នៅយូរអង្វែងដល់អ្នកក្រីក្រជនបទ ។

## ២.២.៤ ការតាមដាន

អ្នកផ្តល់ពត៌មានខ្លះបានបង្ហាញ ការប្រើប្រាស់ការតាមដានសុខភាព តាមដានពីជីវិត និងបរិស្ថាន ជាការការពារសុខភាពសហគម ទប់ទល់នឹងបញ្ហា POPs និងសារធាតុគីមីដែលគ្រោះថ្នាក់ ។

ជាការពិត IPEP បានគាំទ្រគម្រោងទាក់ទងនឹងការតាមដាន កន្លែងរងការបំពុល ដូចជា អ្នកនេសាទប្រឆាំងជាតិពុល ធ្វើការវិភាគជាតិពុល POPs ក្នុងបរិស្ថាននៅតំបន់ឈូងសមុទ្រម៉ានីល ។ ឡាកាបា សិក្សាពី POPsនៅក្នុងសហគមន៍ទីជម្រាលដែលរងប៉ះពាល់ថ្នាំពុលកសិកម្ម ។ អ្នកជំនួយវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាដើម្បីប្រជាជន ធ្វើការតាមដានសហគមដែលប៉ះពាល់សារធាតុភីស៊ីប៊ី និងក្រុមការងារប្រជាជនដើម្បីបោសសំអាតមូលដ្ឋាន ធ្វើការវាយតម្លៃសុខភាពសហគមជនជាតិភាគតិច ក្នុងភូមិមួយដែលកខ្វក់សារធាតុ ភីស៊ីប៊ី ។

ការតាមដានសកម្មភាពថ្នាំពុលនៅសហគមន៍ អនុវត្តដោយបណ្តាញការងារសកម្មភាពថ្នាំពុលកសិកម្មតំបន់អាស៊ីនិងប៉ាស៊ីហ្វិក បានបណ្តុះបណ្តាល និងផ្តល់អំណាចដល់សហគមមូលដ្ឋាន បំពេញពត៌មានស្តីពីឥទ្ធិពលថ្នាំពុលលើសុខភាពមនុស្ស និងបរិស្ថាន តាមការតាមដានសហគម ព្រមទាំងជួយសហគមដែលទទួលការប៉ះពាល់ដើម្បីផ្តល់ពត៌មាន និងរៀបចំសកម្មភាពដោយខ្លួនឯងដើម្បីកាត់បន្ថយហានិភ័យដែលបង្កឡើងដោយការប្រើប្រាស់ និងប៉ះពាល់ថ្នាំពុលកសិកម្ម ហើយទទួលយកការអនុវត្តកសិកម្មតាមគោលការណ៍ធម្មជាតិ ។

ជាផ្នែកមួយនៃការតាមដានអន្តរជាតិរបស់ IPEN ជ្រើសរើសសំណាកស៊ុតពី POPsកើតដោយអចេតនា សហពលបៃតងការីត សហពលសំរាមបរិស្ថាន GAIA និង អង្គការព្យាបាលសុខភាពដោយគ្មានទុក្ខទោស បានប្រមូលស៊ុតមាន់នៅក្បែរ ឧបករណ៍ឡដុតរំលាយសំរាមពេទ្យនៅទីក្រុង ទ្រីសម៉ាទ្រី បង្កើតបានជាទិន្នន័យថា នៅក្នុងស៊ុតនៅប្រទេសហ្វីលីពីន មាន POPs ហើយផ្តល់សម្ភារៈបន្ថែមក្រុមតស៊ូ ដើម្បីបង្ខំយ៉ាងខ្លាំង ឱ្យមានហាមការដុតរំលាយក្រោមដំណើរការខ្យល់ស្អាត និងដំណើរការគ្រប់គ្រងសំរាមរឹងតាមគោលការណ៍បរិស្ថាន ។

## ២.២.៥ ការជំរុញ និងវិស្សោតកម្មសុវត្ថិភាព ~ ជំរើសផ្សេងៗដែលមិនពុល

តាមការស្ទាបស្ទង់បានបង្ហាញថាកាប្រឹងប្រែងពិតប្រាកដរបស់NGOs ក្នុងតំបន់ អនុវត្តដោយសុវត្ថិភាព និងការជំនួសគ្មានជាតិពុល ជាពិសេសការផលិតចំណីអាហារ និង ការគ្រប់គ្រងសំរាម ។

អ្នកផ្តល់ពតិមានក្នុងការស្ទាបស្ទង់ ធ្វើការលើផ្នែក សុវត្ថិភាពចំណីអាហារ សន្តិសុខស្បៀង និង អធិបតេយ្យស្បៀង បានបង្ហាញការគាំទ្រ និងការជំរុញកសិកម្មអេកូឡូស៊ី ដើម្បីកាត់ផ្តាច់ការពឹងផ្អែករបស់កសិករលើគីមីកសិកម្ម ជាពិសេស ថ្នាំពុលកសិកម្មពុលដែលបានហាម និង ថ្នាំពុលកសិកម្មដែលឱ្យប្រើបណ្តោះអាសន្នដោយមានលក្ខខណ្ឌ ។

កម្មវិធីអធិបតេយ្យភាពស្បៀងប្រជាជន នៃបណ្តាញសកម្មភាពថ្នាំពុលកសិកម្មនៅអាស៊ីនិងប៉ាស៊ីហ្វិក មានដូចជា កសិកម្មអេកូឡូស៊ី ជាការងារមួយក្នុងចំណោមការងារទាំងបួន។ អង្គការ NGOs ផ្សេងទៀតបានខិតខំប្រឹងប្រែងជំរុញផ្សព្វផ្សាយវិធានការចម្រុះគ្រប់គ្រងដំណាំ និងគាំទ្រសហគមន៍ឱ្យអនុវត្តកសិកម្មសរីរាង្គ ។

ការងារពីបញ្ហាសំរាម និងការបំពុល បានចាប់ផ្តើមពីបញ្ហានយោបាយ ដូចជា គម្រោងបង្ហាញស្តី ការគ្រប់គ្រងសំរាមដោយគ្មានការដុតរំលាយ តាមប្រពន្ធ័គោលការណ៍ដែលហៅគេថា សំរាមសូន្យ ។

ជាឧទាហរណ៍ បាលីហ្វូកូសសហការជាមួយសមាគមអតិថិជនប៉េណាំង សហពលកម្មសំរាមបរិស្ថាន និងGAIA បានចាប់ផ្តើមសេចក្តីព្រៀងនយោបាយស្តីពីសំរាមសូន្យ ជាជំរើសផ្សេងៗដែលគ្មាន POPs ដើម្បីគ្រប់គ្រងសំរាមទីក្រុងក្នុងប្រទេសឥណ្ឌូនេស៊ី ម៉ាឡាស៊ី និង ហ្វីលីភីន ។

គម្រោងការគ្រប់គ្រងសំរាមតាមគោលការណ៍បរិស្ថាន ជាគម្រោងពន្យល់បង្ហាញមួយដែលឧបត្ថម្ភថវិកាពី IPEP នៅអំឡុងពេលប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ២៣ គេបានបង្ហាញពីភាពអាចធ្វើទៅបាននូវ *សំរាមសូន្យ* តាមវិធានការបង្ការ និងកាត់បន្ថយសំរាម រួមទាំងអនុវត្តការបោះចោលសំរាមដែលធ្វើឱ្យកើត POPs តិចបំផុត ។

## ២.២.៦ ការអភិវឌ្ឍស្ថាប័ន

សេចក្តីត្រូវការថវិការបស់អ្នកផ្តល់ពតិមានមានបរិមាណកើនឡើងសំរាប់ពង្រីកការបង្កើនការយល់ដឹងសាធារណៈ និងសកម្មភាពសំខាន់ផ្សេងៗទៀត ។ លទ្ធផលនៃយុទ្ធនាការ និងការយកចិត្តទុកដាក់របស់ប្រពន្ធ័ពតិមានបានសម្រេចដោយជោគជ័យ ឱ្យមានក្រុមសហគមន៍ផ្សេងៗ (ជាធម្មតា អ្នកចូលរួមជាច្រើនក្នុងសកម្មភាពបង្កើនការយល់ដឹងសាធារណៈបានចាប់ផ្តើមអនុវត្តដោយ NGOs) បានបង្ហាញពីបំណងចង់ធ្វើការការបណ្តុះបណ្តាល កសាងសមត្ថភាព បង្កើនការយល់ដឹងដល់មូលដ្ឋាន ការស្រាវជ្រាវ និងការគាំទ្រដោយខ្លួនឯង។ ពួកគេបានសំដែងនូវការចាប់អារម្មណ៍ក្នុងយុទ្ធនាការជាតិ និងអន្តរជាតិ ដូចជា យុទ្ធនាការ "ទិវាគ្មានថ្នាំពុលកសិកម្ម"។ ការបង្ហាញចំណាប់អារម្មណ៍ទាំងនេះបាននាំឱ្យមានតំរូវការថវិកាកើនឡើងដើម្បីជួយគាំទ្រ មិនចំពោះតែក្រុមធំៗក្នុងសហគមពាក់ពន្ធ័ធ្វើការកសាងសមត្ថភាពទេ គឺថែមទាំងដើម្បីនិរន្តរភាព និង ចលនារបស់ជាតិ និងតំបន់ សម្រេចបានតាមគោលបំណង *អនាគតគ្មានជាតិពុល* កាន់តែជឿនលឿនទៅមុខទៀត ដែលសព្វថ្ងៃមានតំបន់កាន់តែច្រើន បើប្រៀបធៀបនឹង ២-៣ ឆ្នាំមុន ។

NGOs និង ក្រុមប្រជាជនមូលដ្ឋានជាច្រើនចាប់អារម្មណ៍ចូលរួមនឹងបណ្តាញការងារដែលមានធនធានមនុស្សច្រើន ក្រុមលះបង់នៅថ្នាក់មូលដ្ឋាន និងថ្នាក់កណ្តាល ដែលសុខចិត្តចំណាយពេលស្ម័គ្រចិត្ត ឬយកកំរៃយ៉ាងតិចបំផុត គាំទ្រដល់ អនាគតគ្មានជាតិពុល ។

តំរូវការដ៏ធំទាំងនេះបានស្នើដល់ស្នូលតំបន់ និង NGOថ្នាក់ជាតិ មានធនធានរដ្ឋបាល និងហិរញ្ញវត្ថុ ដែលអាចទទួលបានមូលនិធិពីខាងក្រៅ។ NGOs ខ្លះកំពុងប្រឹងប្រែងបង្កើនកំរៃក្នុងមូលដ្ឋាន តាមរយៈការរៃអង្គាស និងគម្រោងសហគមដែលជាចំណូលមានសក្តានុពលភាព។ NGOs ជាច្រើន (ដូចជានៅប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីភីន ) មានកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល និងអង្គភាពដទៃទៀត ដើម្បីបង្កើនធនធានហិរញ្ញវត្ថុ និង អនុវត្តសកម្មភាពតាមផែនការដែលបានកំណត់ក្នុងគោលបំណងយុទ្ធសាស្ត្ររបស់ពួកគេ ។

អ្នកផ្តល់ពតិមានខ្លះទទួលជំនួយពីមូលនិធិឯកជនដែលមានមូលដ្ឋានច្រើនមាននៅអឺរ៉ុប និងសហរដ្ឋអាមេរិក ។ ជំនួយសំរាប់ចំណាយលើរដ្ឋបាល និងប្រតិបត្តិការចាំបាច់ និងសំរាប់អនុវត្តសកម្មភាពគម្រោងរបស់ NGOs មានដូចជា ការស្រាវជ្រាវ ការផលិត និងការចែកផ្សាយសម្ភារៈពតិមាន ការអប់រំ និងការទំនាក់ទំនង ជំនាញបណ្តុះ បណ្តាល ការរៀបចំសហគម ការធ្វើយុទ្ធនាការ និងការគាំទ្រការអភិវឌ្ឍន៍សហគ្រាស និងជីវភាពរស់នៅ។ ចម្លើយតបនឹងសកម្មភាពពីបញ្ហាសុវត្ថិភាពសារធាតុគីមី ទាំងនេះមានថវិកា សំរាប់រយៈពេលតែ ៦ខែ ទៅ ១២ ខែ ប៉ុណ្ណោះ ។

## ៣. ផែនការសកម្មភាពក្នុងតំបន់ : ឱកាស និង តំរូវការ

### ៣.១ គ្រោងការយុទ្ធសាស្ត្ររបស់ NGO តំបន់

លទ្ធផលរបស់គម្រោង IPEP អាស៊ីអាគ្នេយ៍ បានកត់សំគាល់ពី កំណើនសកម្មភាពជាតិ និងសហគមទាក់ទងនឹង POPs ។ "ប្រសិទ្ធិភាពនៃការពង្រីកសកម្មភាព" របស់ស្នូលតំបន់ជួយអនុវត្តអនុសញ្ញាស្តុកខូម ទំនងជាមិនធ្លាប់មានពីមុខមកទេ ។

នៅមុនគម្រោង IPEP ស្ទើរតែគ្មានមានពតិមាន ការបង្កើនការយល់ដឹងសាធារណៈ ការស្រាវជ្រាវ និងសកម្មភាពគាំទ្រទាក់ទងនឹងបញ្ហា POPs នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់សហគមឡើយ ។ វាដូចជាបានប្រមែប្រមូលរបាយការណ៍គម្រោងយ៉ាងច្រើន កម្លាំងដ៏ធំសម្បើម និងត្រូវបានប្រគល់ដោយប្រយ័ត្នប្រយែងបំផុតពីបញ្ហា POPs តាម វិស័យផ្សេងៗក្នុងសង្គម រួមទាំងរដ្ឋាភិបាល ផងដែរ ។

### លទ្ធផលត្រលប់

*" គម្រោង IPEP ជួយចងក្រងឯកសារស្តីពី ការតស៊ូប្រឆាំងរបស់ប្រជាជនចំពោះ ឡដុតរំលាយនៅប្រូហ្កា បានផ្តល់មធ្យោបាយថ្មីមួយដែលមិនមានផលប៉ះពាល់ដល់សហគម។ ជាប្រយោល ឯកសារនេះបានជួយលើកទឹកចិត្ត ពួកគាត់ឱ្យមានសម្លេងកាន់តែខ្លាំង។ លទ្ធផលនៃគម្រោងនេះបានលឿនទៅមុខយ៉ាងខ្លាំង និងបានទទួលយកការទាក់ទងផ្ទាល់របស់យើង " (ក្រុមចងក្រងឯកសារប្រូហ្កា ម៉ាឡេស៊ី)*

*"IPEN បានជួយការខំប្រឹងប្រែងឥតឈប់ឈររបស់យើង ដើម្បីគាំទ្របំរាមរបស់ប្រទេសស្តីពីការដុតរំលាយដោយសេចក្តីព្យាយាមរបស់ IPEP ដូចជា គម្រោងយកសំណាកស៊ុតក្បែរកន្លែងចាក់ចោលសំរាមកខ្វក់ពីមន្ទីរពេទ្យ ។ IPEP ក៏ជួយបង្ហាញយើងពីអ្វីដែលអាចធ្វើបាន មានតម្លៃថោក និងជំរើសតាមគោលការណ៍បរិស្ថាន ចំពោះការដុតរំលាយសំរាមទីក្រុង ដោយកាត់បន្ថយសំរាម និងការបង្កើតឌីអុកស៊ីន និងធាតុពុលដទៃឱ្យនៅកំរិតតិចបំផុត ។" ( សហពលកម្មសំរាមបរិស្ថាន ហ្វីលីភីន)*

*"IPEN មានប្រភពពត៌មានសំខាន់នានាស្តីពី បញ្ហាសុវត្ថិភាពសារធាតុគីមី ហើយបានផ្តល់ករណីសិក្សាអន្តរជាតិ ក៏ដូចជា វិចារណ៏ និងអនុសាសន៍ ពីបណ្តាញការងារធនធានមនុស្ស ។" ( CAIN ថៃ)*

មិនមានការបញ្ជាក់ច្បាស់លាស់នូវចំនួនមនុស្សពិតប្រាកដ ដែលបានដឹងពីការងារទាក់ទងនឹង POPs និង ក៏មិនមានការសិក្សាបញ្ជាក់ពីការផ្លាស់ប្តូរឥរិយាបថ និងនយោបាយ ដែលជាលទ្ធផលនៃការងារទាំងនោះដែរ តែការវាយតម្លៃយ៉ាងរហ័សរបស់អង្គការដៃគូរដែលបានធ្វើរួចហើយ បានណែនាំស្មារតីរបស់អង្គការដៃគូរផ្សេងៗនូវចំនួនដ៏លើសលុប មិនត្រឹមតែបញ្ហា POPs ទេ គឺថែមទាំងផ្តោតលើបញ្ហាសារធាតុគីមីពុល សុខភាពសាធារណៈ និងបរិស្ថានទៀត ផង ។

ទោះបីយ៉ាងណា នៅអំឡុងពេលសកម្មភាពរបស់ IPEP បានគ្របដណ្តប់លើមូលដ្ឋានយ៉ាងច្រើន ក៏នៅមានតំបន់ពាក់ពន្ធ័ជាច្រើនដែលទាមទារឱ្យយកចិត្តទុកដាក់ ហើយរបាយការណ៏បានសរសេរត្រួសៗពីការលេចឡើងនូវ "ស្ថានភាពគ្រោះថ្នាក់របស់ POPs" ។ ដូច្នេះ តំរូវការរៀបចំយន្តការសកម្មភាពលើកទឹកចិត្ត និងតាមផ្តល់យោបល់ មិនគួរឱ្យបាត់បង់ពីចលនាដែលបង្កើតឡើងដោយសកម្មភាព IPEP ដ៏រំជើបរំជួលនេះទេ។ បន្តការគាំទ្រសកម្មភាពមូលដ្ឋានលើបញ្ហា POPs និងសារធាតុគីមីពាក់ពន្ធ័ផ្សេងទៀត នឹងការពារការរសាយចំណាប់អារម្មណ៏ និងកម្លាំង ហើយធ្វើឱ្យ NGOs មានកម្លាំងពលំដណ្តើមយកឱកាសថ្មី ដើម្បីផ្លាស់ប្តូរឥរិយាបថ និងនយោបាយដែលត្រូវតែរបើកឡើង ។

អ្នកអនុវត្តគម្រោង IPEP បានអនុវត្តមិនប្រែប្រួលលើបញ្ហា POPs ពីទស្សនវិស័យធំ សង្គមចម្រុះ នយោបាយ សេដ្ឋកិច្ច និងបរិស្ថានយុត្តិធមិ ។ ការស្ទើចសរសើរពីកម្លាំង និងភាពអំណត់របស់ដៃគូគម្រោង IPEP ជាពិសេសអ្នកដែលធ្វើការនៅមូលដ្ឋានផ្ទាល់ ចង្អុលបង្ហាញពីអត្តចរិតញ៉ាំងឱ្យចង់អនុវត្តអនុសញ្ញាស្តុកខូម និង ប្តេជ្ញាយ៉ាងមុតមាំរបស់ដៃគូរ IPEN ធ្វើការឱ្យសម្រេចនូវ អនាគតគ្មានជាតិពុល ។

## ៣.១.១ ការពង្រឹង ការទំនាក់ទំនង ការសហការ និងការចែកចាយពត៏មានរបស់អន្តរអង្គការ NGO

ការគាំទ្រ និងពង្រីកការផ្តល់ពត៌មាន( យុទ្ធនាការ វិទ្យាសាស្ត្រ បច្ចេកទេស ហិរញ្ញវត្ថុ និងកសាង សមត្ថភាព) នឹងជួយផ្តើមគំនិត NGO មូលដ្ឋានលើបញ្ហា POPs និងសុវត្ថិភាពសារធាតុគីមី ឃើញថាមានសារៈសំខាន់ ដើម្បីបង្កើតភាពជោគជ័យ និង មេរៀនបទពិសោធន៏ នៅពេលអនុវត្ត IPEP ក្នុងតំបន់។

***ប្រភេទការងារ***

១. ពង្រឹង និងពង្រីកបណ្តាញការងារ NGOs ក្នុងតំបន់ដែលធ្វើការលើបញ្ហា POPs និង សុវត្ថិភាពសារធាតុគីមី

២. កំណត់ចំនួន NGOs ដៃគូរដែលអាចបំរើយុទ្ធនាការ ឬគម្រោងរបស់តំបន់

៣. ចាប់យកក្រុមដទៃទៀតនៅអាស៊ីអាគ្នេយ៍ ឬ អាស៊ី ជាតំបន់រួម ដើម្បីពិនិត្យពិច័យពីការសហការគ្នា ឬការខិតខំប្រឹងប្រែងរួមគ្នា ពី បញ្ហាសុវត្ថិភាពសារធាតុគីមី ។

៤. ថែរក្សា និងអភិវឌ្ឍការផ្លាស់ប្តូរពត៌មាន តាមមធ្យោបាយទំនាក់ទំនងផ្សេងៗ រួមមានទាំង ការបង្កើតគេហទំព័រវេបសាយ បញ្ជីសេវាអ៊ីម៉ែល ។ល។

៥. រុករកការចែករំលែកថែមទៀតពីប្រភពពត៌មាន និងចំណេះដឹង រួមមាន ភាពជាដៃគូយុទ្ធនាការ ឬសកម្មភាពការងារ ។

## ៣.១.២ ការពិភាក្សារកិច្ចព្រមព្រៀង និងនយោបាយអន្តរជាតិសំរាប់ការងារជាតិ

ទិដ្ឋភាពនៃកិច្ចព្រមព្រៀងពហុភាគី ជាពិសេស ទំនាក់ទំនងសុខភាពសាធារណៈ និងបរិស្ថាន ត្រូវបានប្រើជាជំនួយដល់ការគាំទ្រ មូលដ្ឋាន និងជាតិ ដើម្បីលុបបំបាត់ POPs ហើយជំរុញ ការគ្រប់គ្រងតាមគោលការណ៍ បរិស្ថានត្រឹមត្រូវលើសារធាតុគីមី និងសំរាមប្រកបដោយជាតិពុល និងគ្រោះថ្នាក់ ។ លើសពីនេះ កិច្ចព្រមព្រៀង អន្តរជាតិសង្គមស៊ីវិលអាចប្រើសេចក្តីថ្លែងការណ៍ តាមសមាគមព្រជាជាតិអាស៊ីអាគ្នេយ៍រួមមាន " សេចក្តីប្រកាសរបស់អាស៊ានស្តីពី និរន្តរភាពបរិស្ថាន" ទើបតែទទួលយកថ្មីៗនៅ ខែ វិច្ឆិកា ២០០៧ ដោយថ្នាក់ដឹកនាំរដ្ឋ រដ្ឋាភិបាល ។

***ប្រភេទការងារ***

១. ផ្តល់ពត៌មាន និងណែនាំដល់ NGOs ពីរបៀបប្រើប្រាស់ និងធ្វើឱ្យកាន់តែធំបំផុតនូវផ្នែកអនុសញ្ញា កិច្ចព្រមព្រៀងសារធាតុគីមី នៅក្នុងការគាំទ្រ និងយុទ្ធនាការរបស់ NGO ដើម្បី អនាគតគ្មានជាតិពុល ។

២. ស្វែងរកសេចក្តីយល់ព្រមរបស់ NGO/CSO សំរាប់ "សេចក្តីថ្លែងការសាកលរួមរបស់ NGO/CSO ស្តីពីយុទ្ធសាស្រ្ត ឆ្ពោះទៅ ការគ្រប់គ្រងសារធាតុគីមីអន្តរជាតិ " ។

៣. ធ្វើសកម្មភាពបង្កើនសមត្ថភាព និងយុទ្ធសាស្រ្ត លើបញ្ហាសុវត្ថិភាពសារធាតុគីមី ដែលប្រើប្រាស់ កិច្ចព្រមព្រៀងសាកលជា អនុភាពនៃការងារជាតិ ។

៤. សិក្សា និងពិនិត្យពិច័យលើដំណើរការកិច្ចសន្យាជាមួយ ក្រុមតំបន់ដូចជា អាស៊ាន និងក្រុមពាក់ពន្ធ័បន្ទាប់ ដែលមានសក្តានុពល ធ្វើឱ្យជឿនលឿន ដល់របៀបវរៈរបស់ប្រជាជន ស្តីពី អនាគតគ្មានជាតិពុល ។

## ៣.២ តំរូវការរបស់ NGO នៅថ្នាក់មូលដ្ឋាន

### ៣.២.១ កសាងសមត្ថភាព និងបណ្តុះបណ្តាល

NGOsបានទទួលស្គាល់ពីតំរូវការសំរាប់កសាងសមត្ថភាព និងការបណ្តុះបណ្តាល ដើម្បីឱ្យពួកគេក្លាយជា អ្នកចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការរៀបចំគោលនយោបាយនៅថ្នាក់ជាតិ និងមូលដ្ឋាន។ សមត្ថភាពបច្ចេកទេស រួមមាន ការអាចជា អ្នកជំនាញការវិទ្យាសាស្ត្រ និងការប្រើប្រាស់បច្ចេកវិជ្ជាសមរម្យឱ្យមានប្រយោជន៏ ។ វាជាភាពខ្វះចន្លោះដែលត្រូវដោះស្រាយក្នុងចំណោម NGOs ដៃគូរ។ បង្កើនសមត្ថភាពបច្ចេកទេស នឹងផ្តល់អំណាច ដល់ NGOs ជំរុញច្បាប់ និងនីតិកម្ម ប្រកបដោយជោគជ័យ ក្នុងការកាត់បន្ថយ ឬលុបបំបាត់សារធាតុគីមីគ្រោះថ្នាក់ ដូចជាការីកចំរើនដោយសុវត្ថភាព-ជំរើសគ្មានជាតិពុល ។

***ប្រភេទការងារ***

១. ស្វែងរក និងអភិវឌ្ឍចំណងទាក់ទងជាមួយអ្នកជំនាញដែលអាចផ្តល់ការគាំទ្របច្ចេកទេស និងវិទ្យាសាស្ត្រដល់ NGOs ដូចជា

ក) សរសេរ ពិនិត្យសើរើ ឬ រិះគន់ នូវឯកសារគោលនយោបាយ ឯកសារបច្ចេកទេស ឯកសារការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឯកសារពតិមានដែលពាក់ពន្ធ័

ខ) ដើរតួរជាធនធានមនុស្ស ដល់ការកសាងសមត្ថភាព ការបណ្តុះបណ្តាល និងសកម្មភាពផ្ទាល់ក្នុងមូលដ្ឋាន

គ) ជួយក្នុងការងារទំនាក់ទំនងសមាជិកសហគម ពាក្យបច្ចេកទេស ដែលអាចឱ្យមនុស្សទូទៅអាចយល់ច្បាស់ពីបច្ចេកទេសសាំញ៉ាំ

ឃ) ផ្តល់ការណែនាំពីទីកន្លែងដែលអាចទៅរកទិន្នន័យពាក់ពន្ធ័

ង) ធ្វើជាកស្សិណសាក្សី ជាអ្នកដឹងឮ និង

ច) និយាយជាមួយ ប្រពន្ធ័ផ្សាយពតិមាន និង អ្នកធ្វើគោលនយោបាយ

### ៣.២.២ ការបណ្តុះបណ្តាលអភិវឌ្ឍស្ថាប័ន

តំរូវការស្ថាប័ន និងហិរញ្ញវត្ថុបាន និងកំពុងកើនបរិមាណដើម្បីធ្វើការពង្រីកបង្កើនការយល់ដឹងសាធារណៈ និងសកម្មភាពដទៃទៀត ។ ដូចលទ្ធផលជោគជ័យនៃយុទ្ធនាការ និងការយកចិត្តទុកដាក់ពីប្រពន្ធ័ពតិមានកន្លងមក ក្រុមសហគមជាច្រើន (តាមធម្មតា អ្នកចូលរួមក្នុងសកម្មភាពបង្កើនការយល់ដឹងសាធារណៈចាប់ផ្តើមដោយ NGOs)បានសំដែងនូវសេចក្តីប្រាថ្នាចងធ្វើការបណ្តុះបណ្តាល បង្កើនសមត្ថភាព ដើម្បីទទួលរ៉ាប់រង ការបង្កើនការយល់ដឹង ការស្រាវជ្រាវ និងការគាំទ្រមូលដ្ឋានដោយខ្លួនឯង ។

***ប្រភេទការងារ***

១. កសាងសមត្ថភាពស្ថាប័ន ដើម្បីឆ្លើយតបនឹងសំណើដៃគូរបណ្ដាញ សំរាប់ការបណ្ដុះបណ្ដាល និង ពង្រីកសកម្មភាព និង យុទ្ធនាការ បង្កើនការយល់ដឹងសាធារណៈ ។

២) អភិវឌ្ឍយុទ្ធសាស្ត្ររៃអង្គាសថវិកា( ថ្នាក់សាកល តំបន់ ឬមូលដ្ឋាន) ដើម្បីប្រមូលធនធាន ជួយគាំទ្រ ប្រជាជន រួមមានការពារសិទ្ធិនៃ NGOs បានទទួលថវិកា។

៣) អភិវឌ្ឍទំនាក់ទំនងយូរអង្វែងជាមួយអង្គការប្រជាជនមូលដ្ឋាន ជំនួយដល់ការគាំទ្រគ្រឹះសង្គម( ឧទាហរណ៍ សិទ្ធិមនុស្ស ដីធ្លី អធិបតេយ្យភាពស្បៀង) និងលើកទឹកចិត្តពួកគេឱ្យដាក់បញ្ចូលរបៀបវារៈគ្មានជាតិពុល ទៅក្នុងគោលបំណង និងផែនការរបស់ពួកគេ ។

## ៣.២.៤ ការតាមដានៈ បរិស្ថាន និងមនុស្ស ៈ បង្កើតទិន្នន័យ

ក្រុមមនុស្សដែលពាក់ពន្ធ័ត្រូវស្វែងរក ប្រមូល និងធ្វើឱ្យមានទិន្នន័យទ្បេងទាត់ ដែលអាចជឿទុកចិត្តបាន ដែលមានប្រសិទ្ធភាពក្នុងសកម្មភាពបង្កើនការយល់ដឹងសាធារណៈ និងការគាំទ្រនយោបាយរបស់ពួកគេ ។ ពួកគេត្រូវបង្កើន សមត្ថភាពរបស់ពួកគេផ្ទាល់ ជាមួយអង្គការប្រជាជនមូលដ្ឋាន ធ្វើការស្រាវជ្រាវ និងតាមដានវិទ្យាសាស្ត្រនិងលក្ខណៈ ដែលជឿបាន។ ទោះបីយ៉ាងណា ពួកគេមិនគួរចូលអន្ទាក់ក្នុងគំរូសព្វថ្ងៃដែលហៅថា " វិទ្យាសាស្ត្រត្រឹមត្រូវ" ចូលរួម នឹងវិទ្យាសាស្ត្រ ដែលត្រួតត្រាការគិត និងការងារនយោបាយរបស់រដ្ឋាភិបាល និងអន្តរដ្ឋាភិបាលជាច្រើន ។ ក្រុមសាធារណៈពាក់ពន្ធ័ ត្រូវការការពារវិទ្យាសាស្ត្រប្រជាជន ប្រមូលចំណេះដឹង និងបទពិសោធន៍មូលដ្ឋាន និងការរៀបចំវិទ្យាសាស្ត្រមិនត្រួតត្រាដោយ ចំណាប់អារម្មណ៍ក្រុមហ៊ុន ។ ក្រុមសាធារណៈពាក់ពន្ធ័ នឹងការពារគោលការណ៍ប្រុងប្រយត្ន័ មិនអនុញ្ញាតឱ្យកង្វះខាតទិន្នន័យវិទ្យាសាស្ត្រ ដើម្បីពន្យារ វិធានការការពារ សុខភាព និងបរិស្ថាន ។

***ប្រភេទការងារ***

១. អភិវឌ្ឍសមត្ថភាពទទួលធ្វើ ការសិក្សាស្រាវជ្រាវ និងតាមដានដោយមានការចូលរួមពីសហគម ជាពិសេស ការតាមដានសុខភាព ការតាមដានជីវិត និងការតាមដានបរិស្ថាន។

២. ផ្ដល់ការបណ្ដុះបណ្ដាល និងជំនួយដល់ដៃគូសហគម ដើម្បីធ្វើកាស្រាវជ្រាវ និងការតាមដាន ដោយមានការចូលរួម

៣. ធ្វើគម្រោងសិក្សាស្រាវជ្រាវ និងការតាមដានដោយមានការចូលរួម ដើម្បី បង្កើនសមត្ថភាព ការបង្កើនការយល់ដឹងសាធារណៈ និងការគាំទ្រ នយោបាយ។

# ៤. សេចក្ដីបញ្ចប់

NGOs នៅអាស៊ីអាគ្នេយ៍កាន់តែច្រើនឡើង ចាប់អារម្មណ៍នឹងយុទ្ធនាការ អនាគតគ្មានជាតិពុល និងបានសំដែងសេចក្ដីប្រាថ្នាចង់អនុវត្ត គម្រោង និងសកម្មភាពដេញដោលអនុសញ្ញាស្ដុកខូមស្ដីពី POPs SAICM និងកិច្ចព្រម

ព្រៀងទាក់ទងនានា។ នៅពេលមានការតាំងចិត្តចំពោះបញ្ហាទាំងនេះដែលធ្វើឱ្យមានឥទ្ធិពលដល់សុខភាព និង បរិស្ថានរបស់ប្រជាជន ក្រុមទាំងនេះត្រូវបានបង្ខាំង ដោយកង្វះខាតសមត្ថភាពប្រកបដោយប្រសិទ្ធភាព និងភាពម៉ឺងម៉ាត់ឆ្លើយតបកំណើនការងារដ៏លំបាកដើម្បីគាំទ្រ និងមូលដ្ឋានកម្មវិធី ។

កំណើនការយល់ដឹងសាធារណៈយ៉ាងខ្លាំងពី ជាតិពុលបាននិងកំពុងកើតក្តីសង្ឃឹម និងតំរូវការ នាំឱ្យមានសំណើរលើការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពកើនឡើង។ ស្ថានភាពនេះតែងតែទាមទារសមត្ថភាព NGOs និងធនធានមនុស្សរបស់ពួកគេ (ជាពិសេស ពេលវេលារបស់ពួកគេ) ឆ្លើយតបនឹងសំណើទាន់ពេលវេលា ។ វាកើន ឡើងយ៉ាងខ្លាំងនូវតំរូវការ របស់ NGOs លើផ្នែកថវិកា និងបច្ចេកទេស ។

ភាគច្រើន NGOs ដែគូរមានការរារាំងដោយ កង្វះសមត្ថភាពរបស់បុគ្គលិក និងសមត្ថភាពរ៉ៃអង្គាសមានកំណត់។ សូម្បីតែថវិកាមានសំរាប់គម្រោងសុវត្ថិភាពសារធាតុគីមីជាក់លាក់ រយៈពេលតែ ៦ខែ ទៅ ១២ ខែប៉ុណ្ណោះ។

អតុល្យភាពរវាងកំណើន NGOs ពាក់ពន្ធ័ធ្វើការលើបញ្ហាជាតិពុល និងអសមត្ថភាពចលនាធនធាន កំពុងក្លាយជាបញ្ហាជាច្រើន ។ នេះជាការកំណត់តំរូវការដើម្បីពង្រឹង និងពង្រីកសមត្ថភាពការគ្រប់គ្រង និងពស្តុភា របស់ NGOs ដើម្បីឱ្យពួកគេ ជួយគាំទ្រ និងពង្រីកការងារបញ្ហា សារធាតុគីមី និងជាតិពុល ។

នៅអាស៊ីអាគ្នេយ៍មានសង្គមស៊ីវិលរស់រវើក និងភាគច្រើនកំពុងធ្វើការ អភិវឌ្ឍគោលនយោបាយសុវត្ថិភាពសារធាតុគីមី និងការងារដែលយើងដឹង ។ វាមានសារៈសំខាន់ណាស់ដើម្បីបន្តការរៀនសូត្រអំពីក្រុម និងរបៀបដែលយើងអាចរួមកម្លាំងពង្រីកសម្លេងរួមគ្នាដល់ អនាគតគ្មានជាតិពុល។ នៅពេលអាស៊ីអាគ្នេយ៍ជាកន្លែង និងកម្មវិធីរបស់អង្គការអន្តរជាតិ អង្គការតំបន់ និងអង្គការអនុតំបន់ ដែលមិនមានការសហការរឹងប៉ឹងកើនឡើង នៅពេលវាហាក់ដូច ជាមាន សក្តានុពលច្រើនសំរាប់កម្លាំង និងការសហការ ។

ជាចុងក្រោយ NGOs ធ្វើការលើបញ្ហាសុវត្ថិភាពសារធាតុគីមី ត្រូវតបទល់នឹងលទ្ធផលគំរាមកំហែងរបស់ជាតិពុល បណ្តាលមកពីការរីកចំរើនសេដ្ឋកិច្ច នៅក្នុងគម្រោងការរបស់អាស៊ាន និងកិច្ចព្រមព្រៀងដៃគូរសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន-ជប៉ុន ដែលបានចចារដោយ រដ្ឋាភិបាល និងមានការចូលរួមពីសង្គមស៊ីវិល តិចតួច ។

ជំហានបន្ទាប់គួរធានាសមត្ថភាពសកម្មភាពតាមដាន សំរាប់ការងារបានចាប់ផ្តើមអនុវត្តហើយ ជាពិសេសការពង្រីកសកម្មភាពបង្កើនការយល់ដឹងសាធារណៈ និងការជួយឱ្យពួកគេរៀបចំសកម្មភាពតាមដានរួមគ្នាដូចជា ការបញ្ចុះបញ្ចូលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ការធ្វើយុទ្ធនាការជាក់លាក់ដើម្បីលុបបំបាត់ ឬកាត់បន្ថយការប្រើប្រាស់សារធាតុពុលដែលមានគ្រោះថ្នាក់ និងការធ្វើសកម្មភាពស្រាវជ្រាវមូលហេតុ ដូចជា ជ្រើសរើសសំណាកបរិស្ថាន និងការតាមដានជីវិត នៅពេលអាចធ្វើបាន ។

ការងារដទៃទៀតគឺការកែលំអសេវាគាំទ្ររដ្ឋបាល និងពស្តុភាររបស់ NGOs ដែលធ្វើការងារសម្របសម្រួល។ ជារើយ១ ថវិកាត្រូវបានកំណត់តែសកម្មភាពគម្រោង ដោយមិនផ្តល់ការគាំទ្រថវិកាចាំបាច់ដល់តំរូវការ រដ្ឋបាល និងពស្តុភា។ ស្ថានភាពនេះ តែងតែទទួលផលពីកង្វះខាតឆ្លើយតបទាន់ពេល ពី សំណើ គាំទ្របច្ចេកទេស និងពន្យារពេល

ផ្តល់របាយការណ៍ និងការផ្តល់លទ្ធផលត្រលប់ពីភាពរីកចំរើនរបស់សកម្មភាព ។

ចន្លោះប្រហោងដែលបានរៀបរាប់ខាងលើ ជាឱកាសសម្រាប់ធ្វើការកែលំអការងារ និងសកម្មភាពនា ពេលខាងមុខ ក្នុងការបង្កើនសមត្ថភាពដើម្បីសម្រេច អនាគតគ្មានជាតិពុល នៅក្នុងតំបន់ ។ គុណប្រយោជន៏នៃការសម្រេចការបង្កើនការយល់ដឹងសាធារណៈ និងសកម្មភាពការងារសហគមន៏ផ្ទាល់ ក្នុងតំបន់ផ្សេងៗ ជាឱកាសដែលពុំមានពីមុនមកនៅក្នុងនយោបាយរបស់រដ្ឋាភិបាលតាមរយៈលទ្ធផលនៃការបញ្ចុះបញ្ចូល និងយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពការធ្វើយុទ្ធនាការយ៉ាងជោគជ័យក្នុងការហាមថ្នាំពុលកសិកម្មជាក់លាក់ និងភាពជោគជ័យដទៃទៀតនៅក្នុងប្រទេស និងសហគមជាច្រើននៅក្នុងតំបន់ ត្រូវតែធ្វើការតាមដាន ដើម្បីការពារផលប្រយោជន៏ និងបង្កើតជំនាក់កាលជោគជ័យធំៗទៀត។ ការប្តេជ្ញាចិត្ត សកម្មភាពប្រយុទ្ធ និងការព្យាយាមជាច្រើននៅក្នុងចំណោម NGOs ដៃគូ និងអង្គការសម្ពន្ធ័ធំៗ ត្រូវការសហគមច្រើនដែលត្រូវបានដាស់តឿន រៀបចំ និង ធ្វើឱ្យមានចលនា ។

សំរាប់ពតិមានបន្ថែម សូមទាក់ទងតាមរយៈ អ៊ីម៉ែល លោក រ៉ូមី romyquij@yahoo.com និង លោកម៉ាននី mannyc@no-burn.org ។

សូមអរគុណ